# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | | |
|---|---|---|
| បញ្ញត្តិកម្ម | : | **សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ជំពូកទី៣. ផ្នែកទី២: ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ (មាត្រា១៣: សកម្មភាពមិនស្របច្បាប់នានារបស់បុគ្គលដែលមានជំហរឧត្តមភាពលើទីផ្សារ)** |
| ក្រសួង | : | ពាណិជ្ជកម្ម |
| លេខយោង | : | ០០៧/ព.ណ |
| កាលបរិច្ឆេទចាប់ផ្តើម | : | ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៧ |
| កាលបរិច្ឆេទបញ្ចប់ | : | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៨ |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ដើម្បីចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) និង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ក៏ដូចជាដើម្បីសម្របខ្លួនចូលក្នុងចរន្តសេដ្ឋកិច្ចទីផ្សារពិភពលោក រាជរដ្ឋាភិបាលកម្ពុជាបានតម្រូវឲ្យបំពេញលក្ខខណ្ឌនានា រួមទាំងការបង្កើតច្បាប់មួយចំនួន ក្នុងនោះច្បាប់ស្តីពី"ការប្រកួតប្រជែង" ក៏ជាលក្ខខណ្ឌដ៏ចំបងមួយផងដែរ ។

ដោយឡែកចំពោះសហគមន៍អាស៊ាន គ្រប់បណ្តាប្រទេសជាសមាជិក បានរម្រូវឲ្យមានច្បាប់ស្តីពី"ការប្រកួតប្រជែង" នៅឆ្នាំ២០១៥ ក៏ប៉ុន្តែគិតពីថ្ងៃចាប់ផ្តើមកសាង រហូតមកដល់ពេលបច្ចុប្បន្ន អស់រយៈកាលជាង ០៨ (ប្រាំបី) ឆ្នាំកន្លងមកហើយ ច្បាប់នេះនៅតែជាសេចក្តីព្រាងនៅឡើយ ដោយសារតែមានកិច្ចពិភាក្សាចំរូងចំរះទៅលើមាត្រាជាច្រើន ក្នុងនោះមាត្រា១៣ ក្នុងផ្នែកទី២ នៃជំពូកទី៣ ដែលចែងអំពី "ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ" ក៏ត្រូវបានចោទជាបញ្ហា មិនទាន់ទទួលបានការយល់ព្រមអនុម័តនៅឡើយ ។

"ជំហរឧត្តមភាពលើទីផ្សារ" សំដៅដល់ស្ថានភាពមួយដែលបុគ្គលណាមួយ ឬ រួមគ្នាជាមួយបុគ្គលផ្សេងទៀតស្ថិតក្នុងជហរលើទីផ្សារក្នុងការធ្វើសកម្មភាពនានា ដោយគ្មានការរារាំង រិតត្បិត ពីគូប្រកួតប្រជែង ឬ គូប្រកួតប្រជែងសក្តានុពលនានា ។

ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំង ១០ គឺប្រទេសចំនួន ០៩ មានច្បាប់ស្តីពី"ការប្រកួតប្រជែង" ដែលនៅក្នុងមាត្រានៃច្បាប់ទាំងនោះក៏មានចែងផងដែរអំពី "ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ" ។

នៅក្នុងកិច្ចសហការដៃគូសេដ្ឋកិច្ច ប្រទេសមួយចំនួនរួមទាំងប្រទេសជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ានផង បានសួរនាំកម្ពុជាអំពីវត្តមាននៃច្បាប់នេះ ក្នុងគោលបំណងចង់បង្កើតធុរកិច្ចថ្មីៗ ដើម្បីចូលរួមចំណែកក្នុងការជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជាបន្ថែមទៀត តាមរយៈការប្រកួតប្រជែងដោយស្មើភាព ដើម្បីផ្តល់

លទ្ធភាពដល់អ្នកប្រើប្រាស់ ឬ អតិថិជនឲ្យទទួលបាននូវ ផលិតផល និង សេវាកម្ម ដែលមានតម្លៃកាន់តែទាប និង ប្រកបដោយគុណភាព ពោលគឺក៏ដូចជាដើម្បីឲ្យមានការធានានូវការទប់ស្កាត់សកម្មភាព ការរារាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែង ដែលធ្វើឡើងតាមរយៈ "ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ" នេះ ។

នៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក៏មានចែងអំពីប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលផ្តល់លទ្ធភាពឲ្យមានការប្រកួតប្រជែងដោយស្មើភាព ក្នុងគោលបំណងដើម្បីជម្រុញឲ្យមានកំនើនវិនិយោគ ក៏ដូចជាធុរកិច្ចថ្មីៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីសម្រេចបាននូវការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការពាណិជ្ជកម្មពិភពលោក និង សហគមន៍អាស៊ានអំពីរឿងនេះ នាយកដ្ឋាននីតិកម្ម និង នាយកដ្ឋានកិច្ចការប្រកួតប្រជែង នៃក្រសួងពាណិជ្ជ-
កម្ម ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ លើការស្រាវជ្រាវ រៀបចំ ចងក្រង និង ជម្រុញដំណើរការតាក់តែងច្បាប់ស្តីពី "ការប្រកួតប្រជែង" ឲ្យបានល្អិតល្អន់ សព្វជ្រុងជ្រោយ និង មានគុណភាពស្របតាមបទដ្ឋានជាតិ និង អន្តរជាតិ ។

មាត្រានេះ នឹងគ្របដណ្តប់លើបុគ្គលទាំងឡាយណាដែលធ្វើសកម្មភាពធុរកិច្ចដោយ រារាំង រិតត្បិត ឬ បង្ខូចការប្រកួតប្រជែងនៅក្នុងទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈ "ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ" ។

ច្បាប់ស្តីពី "ការប្រកួតប្រជែង" មានផ្នែកសំខាន់ៗចំនួន ០៣ (បី) គឺ៖

១/. កិច្ចព្រមព្រៀងរារាំងការប្រកួតប្រជែង (ការព្រមព្រៀងខ្សែផ្តេកមិនស្របច្បាប់ ហៅកាត់ថា កាតែល-Cartel និង ការព្រមព្រៀងខ្សែឈរដែលមិនស្របច្បាប់)

២/. ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ និង

៣/. ការរួមបញ្ចូលគ្នានៃធុរកិច្ច ។ ដែលសកម្មភាពទាំងនេះអាចប្រព្រឹត្តឡើងដោយខុសច្បាប់នៅក្នុងចរន្តសេដ្ឋកិច្ចទីផ្សារសេរី និង បង្កឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ ។

ដូច្នេះនៅក្នុងជំពូកទី៣. ផ្នែកទី២. មាត្រាទី១៣ នៃច្បាប់នេះ (ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ) ក៏ជាផ្នែកមួយយ៉ាងសំខាន់មិនអាចខ្វះបាន ក្នុងការទប់ស្កាត់នូវសកម្មភាពការរារាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែង ។

ដោយសារទីផ្សារកម្ពុជាមានទំហំតូច អាចបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនធំៗ ដែលមាន"ជំហរឧត្តមភាពលើទីផ្សារ" ធ្វើសកម្មភាពរារាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែង **ទើបមាត្រា១៣ នៃសេចក្តីព្រាងច្បាប់នេះត្រូវបានស្នើសុំការយល់ព្រមអនុម័ត** ក្នុងគោលបំណងដើម្បីចូលរួមការពារ និង ជំរុញឲ្យមានការប្រកួតប្រជែងដោយសេរី និង ស្មើភាព ។ លើសពីនេះ គឺដើម្បីបង្កើតឲ្យមានបរិយាកាសអាជីវកម្ម និង វិនិយោគទុនថ្មីៗបន្ថែមទៀត ដោយផ្តល់លទ្ធភាពពិសេសជូនអ្នកប្រើប្រាស់ ឬ អតិថិនឲ្យមានជម្រើសច្រើនក្នុងការស្វែងរកផលិតផល និង សេវាកម្មដែលមានតម្លៃកាន់តែទាប និង ប្រកបដោយគុយភាព ។

**ប្រភេទបញ្ញត្តិកម្ម៖**

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ☑ | ☐ | ☐ | ☐ | ☐ | ☐ | ☐ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖

☑ សេដ្ឋកិច្ច ☑ សង្គមកិច្ច ☑ កសិកម្ម ☐ បរិស្ថាន

## ១. ការកំណត់បញ្ហា

### ១.១. បញ្ហាចម្បងដែលបញ្ញត្តិកម្មនេះមានបំណងដោះស្រាយ

- **ទប់ស្កាត់ការរារាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែងដោយបុគ្គលដែលមាន"ជំហរឧត្តមភាពលើទីផ្សារ"**

ជាទូទៅ នៅក្នុងចរន្តសេដ្ឋកិច្ចទីផ្សារសេរី ប្រសិនបើអាជីវកម្មរបស់បុគ្គលណាមួយ ឬ ក្រុមបុគ្គលណាមួយ មានជំហរឧត្តមភាពលើទីផ្សារហើយ បុគ្គលទាំងនោះតែងតែរិះរកគ្រប់វិធីដើម្បីការពារ និង ពង្រីកអាជីវកម្ម ឬ ស្វែងរកផលចំណេញបន្ថែមទៀតសម្រាប់ខ្លួន ក៏ប៉ុន្តែវិធីដែលពួកគេយកមកប្រើប្រាស់ដើម្បីទទួលបានផលចំណេញកាន់តែច្រើននោះ តែងតែបង្កឲ្យមានផលប៉ះពាល់ដល់គូប្រកួតប្រជែង អតិថិជន អ្នកប្រើប្រាស់ទូទៅ និង សេដ្ឋកិច្ចជាតិផងដែរ ។

សកម្មភាពដែលពួកគេតែងតែប្រព្រឹត្ត គឺរួមមានដូចខាងក្រោម៖

១. ការតម្រូវ ឬ ការបញ្ចុះបញ្ចូលឱ្យអ្នកផ្គត់ផ្គង់ ឬ អតិថិជនមិនឱ្យធ្វើអាជីវកម្មជាមួយគូប្រកួតប្រជែងណាមួយ ឬ គូប្រកួតប្រជែងសក្តានុពល ។

២. ការបដិសេធមិនព្រមផ្គត់ផ្គង់ទំនិញ ឬ សេវាកម្មឱ្យគូប្រកួតប្រជែងណាមួយ

៣. ការលក់ទំនិញ ឬ សេវាក្នុងលក្ខខណ្ឌដែលអ្នកទិញត្រូវទិញទំនិញ ឬ សេវាផ្សេងៗ ដោយឡែកដែលមិនទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យា ។

៤. ការលក់ទំនិញ ឬសេវាកម្មក្នុងតម្លៃទាបជាងថ្លៃដើមផលិត និង

៥. ការបដិសេធមិនឱ្យគូប្រកួតប្រជែងណាមួយ ប្រើប្រាស់មធ្យោបាយចាំបាច់ ។

<u>ជាក់ស្តែងយើងសង្កេតឃើញថា កន្លងមកមានសកម្មភាពរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ ហើយយើងក៏សង្ស័យថា ក្រុមហ៊ុនមួយចំនួនផ្សេងទៀតដែលមានជំហរឧត្តមភាពលើទីផ្សារបានធ្វើសកម្មភាពរាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែងផងដែរដូចជា</u>៖

**ក/- ក្នុងវិស័យទូរគមនាគមន៍៖** នៅឆ្នាំ២០០៨ ក្នុងព្រះរាជាណាចក្រកម្ពុជា មានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចំនួនតែ ០៤ (បួន) ប៉ុណ្ណោះ ។ ក្រោយមកនៅឆ្នាំ២០១០ ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទបានកើនឡើងដល់ចំនួន ១០ (ដប់) ដោយគិតបញ្ចូលទាំងក្រុមហ៊ុនថ្មីមួយដែលទើបបង្កើតផងដែរ ។ ដោយមានការប្រកួតប្រជែងយ៉ាងខ្លាំងក្លា ក្រុមហ៊ុនដែលមានជំហរឧត្តមភាពលើទីផ្សារក្នុងការផ្តល់លទ្ធភាពឲ្យអតិថិជនហៅទូរស័ចេញបានច្រើន (Access to calling) បានប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីបន្ទាបតម្លៃហៅទូរស័ព្ទចេញរបស់ក្រុមហ៊ុនខ្លួនមកត្រឹមតែ ០៤ សេន/នាទី តែប៉ុណ្ណោះ ដែលនេះ*ជាតម្លៃទាបជាងថ្លៃដើមផលិត* ក្នុងគោលបំណងដើម្បីផ្តួលគូប្រកួតប្រជែងបានសិន ទើបអាចតម្លើងថ្លៃហៅចេញឲ្យបានខ្ពស់វិញ ។ ក្រោយពីសង្គ្រាមថ្លៃនេះ (Price War) គឺ

គ្មានគូប្រកួតប្រជែងណាមួយទទួលបានផលចំណេញឡើយ មិនតែប៉ុណ្ណោះថែមទាំងបណ្តាលឲ្យបរិយាកាសអាជីវកម្ម ក៏ដូចជាសេដ្ឋកិច្ចលើវិស័យនេះកាន់តែអាក្រក់ឡើង ដោយធ្វើឲ្យទីផ្សារមិនមានគូប្រកួតប្រជែងទៀតឡើយ ដែលសកម្មភាពទាំងនេះ គឺត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីការប្រកួតប្រជែង ។

ដោយសារព្រះរាជាណាចក្រកម្ពុជាមិនទាន់មានច្បាប់នេះ រាជរដ្ឋាភិបាលបានសម្រេចធ្វើអន្តរាគមន៍ដោយចេញលិខិតប្រកាសអន្តរក្រសួងលេខ: ចុះថ្ងៃទី ខែ ឆ្នាំ២០១៤ ស្តីអំពីការកំណត់តម្លៃ (Predatory Pricing) ហៅទូរស័ព្ទចេញ មិនឲ្យលើសពី 0៤ សេន/នាទី ឡើយ ។

**ខ/- ក្នុងវិស័យដឹកជញ្ជូន:** ក្រុមហ៊ុនមួយចំនួន ដែលមានជំហរឧត្តមភាពលើទីផ្សារផ្នែកដឹកជញ្ជូន អាចបញ្ចុះបញ្ចូលអ្នកផ្តល់សេវាកម្មកំពង់ផែផ្លូវទឹក ឬ កំពង់ផែស្ងួត មិនឲ្យផ្តល់សេវាកម្មដល់ក្រុមហ៊ុនផ្សេងទៀតដែលជាគូប្រកួតប្រជែងរបស់ខ្លួន ដែលសកម្មភាពនេះអាចចូលរួមធ្វើឲ្យតម្លៃនៃការដឹកជញ្ជូនកើនឡើងយ៉ាងខ្ពស់ ។

**គ/- ក្នុងវិស័យកសិកម្ម:** ក្រុមហ៊ុនដែលមានជំហរឧត្តមភាពលើទីផ្សារក្នុងការប្រមូលទិញស្រូវដើម្បីផលិតជាអង្ករសម្រាប់លក់ ឬ នាំចេញ អាច*តម្រូវ ឬ បញ្ចុះបញ្ចូលអ្នកផ្គត់ផ្គង់ ឬ អ្នកផ្តល់សេវាកម្ម*ដែលមានម៉ាស៊ីនច្រូត និងម៉ាស៊ីនសម្ងួតស្រូវ មិនឲ្យធ្វើសេវាកម្មច្រូត ឬ សម្ងួតស្រូវឲ្យប្រជាកសិករណា ដែលមិនលក់ស្រូវឲ្យខ្លួននាពេលប្រមូលផលនោះឡើយ ឬ បញ្ចុះបញ្ចូលអ្នកមានម៉ាស៊ីននោះ ឲ្យផ្តល់សេវាកម្មច្រូត ឬ សម្ងួត នៅដំណាក់កាលចុងក្រោយគេ ដែលការយឺតយ៉ាវនោះអាចធ្វើឲ្យគុណភាព និង បរិមាណស្រូវមានការខូចខាត និងបាត់បង់ ដែលញ៉ាំងឲ្យប្រជាកសិករត្រូវតែបង្ខំចិត្តលក់ស្រូវរបស់ខ្លួនក្នុងតម្លៃថោកបាន ។ល។

**១.២. បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ**

- ចូលរួមចំណែកលុបបំបាត់បាននូវភាពអ៊ូរទាំ កង្វល់ ប្រតិកម្ម ភាពមិនសប្បាយចិត្ត និង បញ្ហាប្រឈមរបស់ អ្នកប្រើប្រាស់ អាជីវករ ពាណិជ្ជករ និង ក្រុមហ៊ុនដែលប្រកបអាជីវកម្មដោយស្មោះត្រង់ ដោយសារការរំលោភបំពានដោយក្រុមហ៊ុនធំ ឬ ក្រុមហ៊ុនដែលមានជំហរឧត្តមភាពលើទីផ្សារ ។
- ចូលរួមលប់បំបាត់របាំងចូលទីផ្សារ ជម្រុញការបង្កើតថ្មី និង បង្កឲ្យមានការប្រកួតប្រជែងកាន់តែប្រសើរឡើង ។
- ចូលរួមបង្កើតទំនុកចិត្តដល់ធុរកិច្ចទាំងក្នុង និង ក្រៅប្រទេស
- ចូលរួមកាត់បន្ថយបាននូវការរងសម្ពាធពីសហគមន៍អន្តរជាតិ អំពីលក្ខខ័ណ្ឌកសាងច្បាប់នេះ ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក៏ដូចជាមាជិកនៃសហគមន៍អាស៊ាន ។
- ចូលរួមកាត់បន្ថយបន្ទុកចំណាយរបស់ផលិតកម្ម សេវាកម្ម របស់ធុរកិច្ចផ្សេងៗ ក៏ដូចជាធ្វើឲ្យតម្លៃផលិតផល និង តម្លៃសេវាកម្ម មានការថយចុះ ។
- ចូលរួមបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋ អ្នកប្រើប្រាស់ អាជីវករ ពាណិជ្ជករ លើរាជរដ្ឋាភិបាល ។
- ចូលរួមកាត់បន្ថយការឧបត្ថម្ភធន និង កិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល ។

- **សំណើបញ្ញត្តិកម្មនេះ** មិនត្រឹមតែមិនមានផលប៉ះពាល់ដល់ការប្រកួប្រជែងតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងចូលរួមការពារមិនឲ្យមាន ការរារាំង រិតត្បិត និង បង្ខូចការប្រកួតប្រជែងទៀតផង ។

## ២. គោលបំណង

មាត្រានេះមានគោលបំណងចូលរួមជំរុញឲ្យមានការប្រកួតប្រជែងដោយស្មើភាព ដោយមិនអនុញ្ញាតឲ្យមានការរំលោភបំពានដោយ "ជំហរឧត្តមភាពលើទីផ្សារ" ឡើយ ដោយផ្តល់ឱកាសឲ្យអតិថិជន ឬ អ្នកប្រើប្រាស់ទទួលបានទំនិញ និង សេវាក្នុងតម្លៃទាប និង មានគុណភាព ។

ទន្ទឹមនឹងនេះ វាក៏ចូលរួមចំណែកជម្រុញឲ្យមានការបង្កើតនូវធុរៈកិច្ចថ្មីៗក្នុងទីផ្សារ ដែលនឹងនាំទៅរកការរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិបន្ថែមទៀត ។

## ៣. ជម្រើស

-ជម្រើសទី១: រក្សាស្ថានភាពដើម (មិនមានមាត្រា១៣. នៃផ្នែកទី២. ជំពូកទី៣ នៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង ) ។

-ជម្រើសទី២: មានមាត្រា១៣. ផ្នែកទី២. ជំពូកទី៣ នៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង ។

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់ព័ន្ធ និង ផលចំណេញ

៤.១. ការកំណត់ភាគីពាក់ព័ន្ធ និង ប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| **ជម្រើសទី១:**<br>រក្សាស្ថានភាពដើម ។ | -ឆ្លើយតបទៅនឹងលក្ខខណ្ឌរបស់ WTO និង សហគមន៍អាស៊ាន ។<br>-រដ្ឋាភិបាលនឹងត្រូវធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ និង ឧបត្ថម្ភធន ។ | -ចំណាយរបស់ផលិតកម្ម សេវាកម្មរបស់ធុរកិច្ចផ្សេងៗ ក៏ដូចជាធ្វើឲ្យតម្លៃផលិតផល និង តម្លៃសេវាកម្មមានតម្លៃខ្ពស់ ។ |
| **ជម្រើសទី២:**<br>សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង(មាត្រា១៣: ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ) ។ | -កិច្ចប្រជុំក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម<br>ជាមួយថ្នាក់ដឹកនាំក្រសួងពា/ណិ អំពីច្បាប់ស្តីពី"ការប្រកួតប្រជែង"បានចំនួន១៥០ (មួយរយហាសិប)លើក ក្នុងនោះអំពីមាត្រា១៣ មានចំនួន ៥០(ហាសិប) លើក ។<br>-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីមានរយៈពេល ៣០ លើក (សាមសិប)លើកក្នុងនោះកិច្ចប្រជុំអំពី | -ចូលរួមសិក្ខាសាលាពិគ្រោះយោប-ជាមួយអាជីវករ ក្រុមហ៊ុន និង ភាគីពាក់ព័ន្ធចំនួន ០៦ (បួន) លើក គិតជាមធ្យម អំពីមាត្រា១៣ ចំនួន ០២ លើក ។<br>-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ/បណ្តុះបណ្តាល ចំនួន ០១ (មួយ) លើក (ចំនួន៦០០ក្រុមហ៊ុនអាជីវកម្ម) ។<br>-ជួលមេធាវី ឬ អ្នកប្រឹក្សាដើម្បី |

| | | |
|---|---|---|
| | មាត្រា១៣ មានចំនួន ០៥ (ប្រាំ) លើក ។<br>-កិច្ចប្រជុំក្រុមការងារបច្ចេកទេសជាមួយ អន្តរក្រសួងអំពីមាត្រា១៣ មានចំនួន ០៥ (ប្រាំ) លើក ។<br>-សិក្ខាសាលាពិគ្រោះយោបល់ជាមួយ អាជីវករ ក្រុមហ៊ុន និង ភាគីពាក់ព័ន្ធមានចំនួន០៦(ប្រាំមួយ) លើក គិតជាមធ្យម សម្រាប់មាត្រា១៣ គឺចំនួន ០២ លើក។<br>-បោះពុម្ពសៀវភៅច្បាប់ចំនួន ១៥០០០ (មួយម៉ឺនប្រាំពាន់)ក្បាល គិតជាមធ្យម សម្រាប់សន្លឹកមាត្រា ១៣ គឺប្រមាណ ៣០០០ (បីពាន់ក្បាល) ។<br>-បង្កើតគណៈកម្មាធិការកិច្ចការប្រកួតប្រជែ-ងមួយដែលមានសមាសភាពសរុបចំនួន ១៣ (ដប់បី) រូប x (២០០០០០០ រៀល)<br>-ចំណាយផ្សេងៗ ។ល។ | ផ្តល់យោបល់ឲ្យក្រុមហ៊ុន និង អាជីវកម្មពាក់ព័ន្ធនឹង សកម្មភាព"រំលោភបំពានដោយ ជំហរឧត្តមភាពលើទីផ្សារ" ចំនួនប្រមាណ ១០០០ក្រុមហ៊ុន ឬ អាជីវកម្ម x៥០០$ ។<br>-ចំណាយផ្សេងៗ ។ល។ |

## ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| **ជម្រើសទី១:** រក្សាស្ថានភាពដើម ។ | -គ្មាន |
| **ជម្រើសទី២:**សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង (មាត្រា១៣: ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ) ។ | - មានច្បាប់ និង យន្តការសម្រាប់អនុវត្តន៍ស្របតាមចរន្តសេ-ដ្ឋកិច្ចពិភពលោក ជាពិសេសជាមួយសហគមន៍អាស៊ាន ។<br>- ជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញ និង សេវាក្នុងតម្លៃទាប មានគុណភាពខ្ពស់ និង មានជម្រើសច្រើន ។<br>- ផ្តល់បរិយាកាសល្អ និង ភាពទាក់ទាញដល់វិនិយោគិនថ្មីៗ ទាំងក្នុង និង ក្រៅប្រទេស ។<br>- បង្កើតបរិយកាសប្រកួតប្រជែងដោយស្មើភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។<br>- ផ្តល់ទំនុកចិត្តដល់ធុរកិច្ចជន/ពាណិជ្ជករ ទាំងក្នុង និង ក្រៅប្រទេសអំពីការធ្វើពាណិជ្ជកិច្ច ។<br>- បង្កលក្ខណៈងាយស្រួលក្នុងការស្រាវជ្រាវ គ្រប់គ្រង និង |

| | |
|---|---|
| | ត្រួតពិនិត្យ អាជីវកម្មលើទីផ្សារ ។<br>- កាត់បន្ថយគ្រោះ នៃអតិផរណាទំនិញ<br>- បង្កើនទំនុកចិត្តពីប្រជាពលរដ្ឋក៏ដូចជាអាជីវករ ពាណិជ្ជករ ក្រុមហ៊ុន មកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ។<br>- ចូលរួមលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរជាងមុន ។<br>- កាត់បន្ថយបន្ទុកចំណាយផ្សេងរបស់ធុរកិច្ច<br>- កាត់បន្ថយការឧបត្ថមធន និង អន្តរាគមន៍នានារបស់រាជរដ្ឋាភិបាល ។ល។ |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬ ប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង ឬ ភស្តុតាង |
|---|---|---|---|
| **ជម្រើសទី១:** រក្សាស្ថានភាពដើម | -អ្នកប្រើប្រាស់/អតិថិជន<br>-ពាណិជ្ជករ /កសិករ<br>-ក្រុមហ៊ុន<br>-សេដ្ឋកិច្ចជាតិ | មិនទាន់កំណត់បាន ។ | មិនទាន់បានស្រាវជ្រាវ ។ |
| **ជម្រើសទី២:** សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង (មាត្រា១៣៖ ការរំលោភបំពានដោយជំហរឧត្តមភាពលើទីផ្សារ) | -អ្នកប្រើប្រាស់/អតិថិជន<br>-ពាណិជ្ជករ / ក្រុមហ៊ុន<br>-សេដ្ឋកិច្ចជាតិ | មិនទាន់កំណត់បាន ។ | មិនទាន់បានស្រាវជ្រាវ ។ |
| | | | |

## ៥. កិច្ចពិគ្រោះយោបល់

-កិច្ចប្រជុំក្រុមការងារបច្ចេកទេសរបស់ នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម ជាមួយថ្នាក់ដឹកនាំក្រសួង ៣/

ណិ អំពីច្បាប់ស្តីពី"ការប្រកួតប្រជែង"បានចំនួន១៥០ (មួយរយហាសិប)លើក ក្នុងនោះអំពីមាត្រា ១៣ មានចំនួន ៥០(ហាសិប) លើក ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីមានរយៈពេល ៣០ លើក (សាមសិប)លើក ក្នុង នោះ កិច្ចប្រជុំអំពីមាត្រា១៣ មានចំនួន ០៥ (ប្រាំ) លើក ។

-កិច្ចប្រជុំក្រុមការងារបច្ចេកទេសជាមួយ អន្តរក្រសួងអំពីមាត្រា១៣ មានចំនួន ០៥ (ប្រាំ) លើក ។

-សិក្ខាសាលាពិគ្រោះយោបល់ជាមួយអាជីវករ ក្រុមហ៊ុន និង ភាគីពាក់ព័ន្ធមានចំនួន០៦(ប្រាំមួយ) លើក គិតជាមធ្យម សម្រាប់មាត្រា១៣ គឺចំនួន ០២ លើក ។ល។

## ៦. សន្និដ្ឋាន

**តើចាំបាច់ត្រូវធ្វើការវាយតម្លៃពេញលេញ (RIS) ដែរឬទេ?**

☑ មិនចាំបាច់

ក្រោយពីបានវិភាគលើបន្ទុកចំណាយ និង ផលចំណេញរួចមក យើងអាចសន្និដ្ឋានបានថា៖

**-ជម្រើសទី១:** រាជរដ្ឋាភិបាលមានការលំបាកក្នុងការតាមដាន ត្រួតពិនិត្យ និង ស្រាវជ្រាវដោយសារមិនមាន លិខិតបទដ្ឋានគតិយុត្តិ / បញ្ញត្តិកម្ម និង យន្តការណាមួយដើម្បីអនុវត្ត ឲ្យស្របតាមបទដ្ឋានអន្តរជាតិ ។ លើសពីនេះ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ អាចនឹងមានការធ្លាក់ចុះតាមរយៈ ការតម្លើងថ្លៃទំនិញ និង សេវាកម្ម ផ្សេងៗផងដែរ ។

**-ជម្រើសទី២:** រាជរដ្ឋាភិបាលនឹងទទួលបានផលចំណេញមួយចំនួនបន្ថែមទៀត ដែលមិនអាចគណនាបានដូចជា៖

- មានច្បាប់ និង យន្តការសម្រាប់អនុវត្តន៍ស្របតាមចរន្តសេដ្ឋកិច្ចពិភពលោក ជាពិសេសជាមួយសហគមន៍អាស៊ាន ។
- ជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញ និង សេវាក្នុងតម្លៃទាប មានគុណភាពខ្ពស់ និង មានជម្រើសច្រើន ។
- ផ្តល់បរិយាកាសល្អ និង ភាពទាក់ទាញដល់វិនិយោគិនថ្មីៗ ទាំងក្នុង និង ក្រៅប្រទេស ។
- បង្កើតបរិយកាសប្រកួតប្រជែងដោយស្មើភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ផ្តល់ទំនុកចិត្តដល់ធុរកិច្ចជន/ពាណិជ្ជករ ទាំងក្នុង និង ក្រៅប្រទេស អំពីការធ្វើពាណិជ្ជកិច្ច ។
- បង្កលក្ខណៈងាយស្រួលក្នុងការស្រាវជ្រាវ គ្រប់គ្រង និង ត្រួតពិនិត្យ អាជីវកម្មលើទីផ្សារ ។
- កាត់បន្ថយគ្រោះ នៃអតិផរណាទំនិញ
- បង្កើនទំនុកចិត្តពីប្រជាពលរដ្ឋ ក៏ដូចជាអាជីវករ ពាណិជ្ជករ ក្រុមហ៊ុន មកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ។
- ចូលរួមលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរជាងមុន ។
- កាត់បន្ថយបន្ទុកចំណាយផ្សេងរបស់ធុរកិច្ច
- កាត់បន្ថយការឧបត្ថមធន និង អន្តរាគមន៍នានារបស់រាជរដ្ឋាភិបាល ។ល។ ដែលផលចំណេញទាំង

នេះ ក៏ជាកក្តាលីករចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយចិរភាពផងដែរ ។

## ៧. ការអនុវត្តន៍ និង ការតាមដានត្រួតពិនិត្យ

បន្ទាប់ពីបានប្រកាសដោយព្រះរាជក្រម ច្បាប់នេះនឹងត្រូវដាក់ឲ្យអនុវត្តជាការប្រញាប់ ។

ច្បាប់នេះ ផ្តល់ឱកាសឲ្យរាជរដ្ឋាភិបាលក្នុងការចេញប្រកាស ឬ អនុក្រឹត្យនានាដែលពាក់ព័ន្ធ និង ចាំបាច់សម្រាប់អនុវត្តន៍ ។

នាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ នៃអគ្គនាយកដ្ឋានកាំកុងត្រូល និង នាយកដ្ឋាននីតិកម្ម នៃ ក្រសួងពាណិជ្ជកម្ម ដែលជាអ្នកប្រឹក្សាយោបល់ ឬ ចាត់ចែងរៀបចំអ្នកពិគ្រោះយោបល់សម្រាប់ដោះស្រាយវិវាទ នឹងត្រូវទទួលខុសត្រូវជាអ្នកស្រាវជ្រាវ ត្រួតពិនិត្រ ចោទប្រកាន់ និង ដោះស្រាយវិវាទដែលកើតចេញពីការ រំលោភបំពានច្បាប់ ឬ មាត្រា១៣ នេះ ។

រៀបចំរបាយការណ៍អំពីសកម្មភាព និង លទ្ធផល នៃការអនុវត្តច្បាប់នេះជូន គ.ប.ក ក៏ដូចជារាជរដ្ឋា-ភិបាលផងដែរ ។

ច្បាប់ ឬ មាត្រានេះ នឹងត្រូវមានការត្រួតពិនិត្យ និង វាយតម្លៃឡើងវិញអំពីផលប៉ះពាល់ / លទ្ធផល ដែលសម្រេចបានពីការអនុវត្តក្នុងរយៈពេល ០៣ (បី) ឆ្នាំ ។

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| រៀបចំដោយ ក្រុមការងារ RIA របស់ ក្រសួងពាណិជ្ជកម្ម (MOC-RIA TEAM)៖ | ឯ.ឧ ប៉ែន សុវិជាតិ | ប្រធាន | ០១២ ៨១៦ ៦៦៣ |
| | លោក យឹម ចំណាប់ភក្តី | អនុប្រធានអចិន្ត្រៃយ៍ | ០១២ ៩៨ ៧៨ ៧៨ |
| | លោក យូ ម៉ាប់ | អនុប្រធាន | ០៨៩ ៧៦ ៧៦ ៨៦ |
| | លោក អេន ឌី | សមាជិក | ០១២ ៨៨០ ៣៤៨ |
| | លោក សំ ចិត្រា | សមាជិក | ០១១ ៦៣៥ ៩៣៥ |
| | លោក គាន សុចិន្តា | សមាជិក | ០១៦ ៦៣៦ ៦៣៥ |
| | លោក ម៉ី គាតុលា | សមាជិក | ០១២ ៨៤៥ ៣៦៧ |
| | លោក សុខ ធីតា | សមាជិក | ០៧០ ៧៩០ ៧៨៩ |
| | លោក ផេង បូរ៉ា | សមាជិក | ០១៧ ៤៥៥ ១២២ |
| | លោក កែវ បុនថេង | សមាជិក | ០១២ ៨០១ ៩៩៦ |
| | លោក ប៉ូច សៀងហៃ | សមាជិក | ០៨៩ ៥១០ ៦០០ |
| | លោក ប៉ា លន់រស្មី | សមាជិក | ០១៧ ៤៥៥ ១២២ |
| ផ្តល់យោបល់ដោយក្រុម RIAរបស់ ECOSOCC៖ | ឯកឧត្តម ប៊ិច សុខា | អ្នកគ្រប់គ្រងគម្រោងRIA | ០១២ ៦៩៨ ៩៩៩ |
| | ឯកឧត្តម អេង រត្នមុនី | ប្រធានក្រុមបណ្តុះបណ្តាល | ០១២ ៩១២ ០០៩ |
| | លោក រ៉ុម ផល្លីស | បុគ្គលិករដ្ឋបាល | ០៧៨ ២៣៥ ០៧៨ |
| | កញ្ញា ហៃ ស្រីលក្ខ | សមាជិក | ០១៦ ៤២៧ ៤២៩ |

រាជធានីភ្នំពេញ ថ្ងៃសុក្រ ៩រោច ខែអស្សុជ ឆ្នាំច. សំរឹទ្ធិស័ក. ព.ស ២៥៦២
ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨
អ្នកធ្វើរបាយការណ៍
**អនុប្រធានអចិន្ត្រៃយ៍ក្រុមការងារ**

**យឹម ចំណាប់ឥក្តី**

បានឃើញ និង ឯកភាព
**ប្រធានក្រុមការងារ**

**ប៉ែន សុវិជាតិ**